# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់**
**និងប្រព័ន្ធយុត្តធម៌**
**អង្គភាពគ្រប់គ្រងគម្រោង**
**លេខ៖ ០០១/០៨ របក.អគគ**

## របាយការណ៍
## ស្តីពី
## សកម្មភាពការងារប្រចាំខែ ធ្នូ ឆ្នាំ ២០០៧
## របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តធម៌
## និងទិសដៅសម្រាប់អនុវត្តបន្ត

ក្នុងខែ ធ្នូ ឆ្នាំ២០០៧នេះ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ ជាអ្នកសម្របសម្រួលដំណើរការប្រចាំថ្ងៃ និងមានអង្គភាពគ្រប់គ្រងគម្រោង ជាអង្គភាពប្រតិបត្តិបានដំណើរការងាររបស់ខ្លួនស្របតាមបេសកកម្ម ដែលបានកំណត់ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ហើយសម្រេចបាននូវលទ្ធផលជាក់ស្តែងដូចខាងក្រោម ៖

### ១-ការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

#### ក. ការងាររដ្ឋបាល

-ផ្ញើលិខិតស្នើសុំផ្តល់យោបល់លើឯកសារស្តីពីការវិភាគតុលាការគំរូកម្ពុជា ទៅសមាជិកក្រុមការងារតុលាការគំរូ កាលពីថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ២០០៧

-ផ្ញើលិខិតស្នើចាត់បញ្ជូនមន្ត្រីជំនាញផ្នែកផែនការហិរញ្ញវត្ថុចំនួន ២ រូប ដែលមានឋានៈស្មើប្រធាន ឬអនុប្រធាននាយកដ្ឋានឱ្យចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការរៀបចំផែនការ និងការគ្រប់គ្រង កាលពីថ្ងៃទី ០៦ ខែធ្នូ ឆ្នាំ២០០៧

-ផ្ញើលិខិតស្នើសុំផ្តល់យោបល់លើសេចក្តីព្រាង អនុក្រឹត្យពាក់ព័ន្ធនឹងការផ្សព្វផ្សាយរាជកិច្ច ទៅអគ្គនាយកនៃអគ្គនាយកដ្ឋានរាជកិច្ចទីស្តីការគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៧

-ផ្ញើដីការអមរបាយការណ៍កិច្ចប្រជុំស្តីពីវិធីសាស្ត្រពង្រឹកបន្ថែមតុលាការគំរូនៅប្រទេសកម្ពុជា ទៅសមាជិកក្រុមការងារបច្ចេកទេសតុលាការគំរូ កាលពីថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ២០០៧

-ផ្ញើលិខិតស្នើសុំបង្កើត Domain មួយឈ្មោះថា WWW.CLJR.GOV.KH ទៅឯកឧត្តមរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ កាលពីថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ២០០៧

-ផ្ញើលិខិតស្នើសុំសៀវភៅច្បាប់រដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី ចំនួន ២០ក្បាល ពីអគ្គលេខាធិការក្រុមប្រឹក្សាអ្នកច្បាប់ ទីស្តីការគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ២០០៧

**ខ. ការងារកំណែទម្រង់**

-រៀបចំកិច្ចប្រជុំក្រុមប្រតិបត្តិគម្រោងសិទ្ធិទទួលបានយុត្តិធម៌នៅកម្ពុជា (Access to Justice) នៅថ្ងៃសុក្រ ទី៧ ខែធ្នូ ឆ្នាំ២០០៧ វេលាម៉ោង ៨.៣០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាព ឯកឧត្តម **ស៊ុំ ម៉ានិត**

-រៀបចំប្រជុំអនុគណៈកម្មាធិការមូលនិធិបត់បែនរបស់គម្រោង CCJAP III នៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៧ វេលាម៉ោង ៩.០០ ព្រឹក ក្រោមអធិបតីភាពឯកឧត្តម **ស៊ុយ ម៉ុងលាង**

-ទទួលឯកសារស្តីពីការរៀបចំទិន្នន័យការបណ្តុះបណ្តាលសិទ្ធិមនុស្ស

-កែសម្រួលសេចក្តីព្រាងតារាងស្តីពីស្ថានភាពនៃការអនុវត្តកម្មវិធីសកម្មភាពកំណែទម្រង់ច្បាប់ និងតុលាការ

-រៀបចំសេចក្តីសម្រេចស្តីពីសមាសភាពក្រុមការងារបច្ចេកប្រព័ន្ធសូចនាករ និងការតាមដានកំណែទម្រង់ច្បាប់ និងតុលាការ

-រៀបចំព្រាងរបាយការណ៍ស្តីពីការអនុវត្តសកម្មភាពកំណែទម្រង់ច្បាប់ និងតុលាការ ឆមាសទី ២ ឆ្នាំ២០០៧។

**២-សន្និដ្ឋាន**

ក្នុងខែ ធ្នូ ឆ្នាំ ២០០៧ នេះ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ ជាអ្នកសម្របសម្រួលដំណើរការប្រចាំថ្ងៃ និងមានអង្គភាពគ្រប់គ្រងគម្រោងជាអង្គភាពប្រតិបត្តិ បានបន្តកិច្ចការពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីសកម្មភាព សម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការទៅតាមអាទិភាព ដែលបានកំណត់ ដោយផ្តោតជាសំខាន់ទៅលើការជម្រុញការអនុវត្តគម្រោងស្តីពីការពង្រឹកបន្ថែមតុលាការគំរូ និងការរៀបចំប្រព័ន្ធសូចនាករ និងការតាមដានកំណែទម្រង់ច្បាប់ និងតុលាការ និងកិច្ចការរបាយការណ៍ ដែលត្រូវរៀបចំសម្រាប់បំណាច់ឆ្នាំ២០០៧ ក៏ដូចជាការងារកែទម្រង់ច្បាប់ និងតុលាការជារួមតាំងពីឆ្នាំ២០០៣-២០០៨។

**៣-ទិសដៅអនុវត្តក្នុងខែបន្ត ឆ្នាំ២០០៨**

-រៀបចំកិច្ចប្រជុំអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ នៅដើមខែកុម្ភៈ ឆ្នាំ២០០៨

-បន្តជម្រុញការអនុវត្តគម្រោងតុលាការគំរូ

-បន្តជម្រុញការអនុវត្តគម្រោងប្រព័ន្ធសូចនាករ និងការតាមដាន

-បន្តជម្រុញការអនុវត្តគម្រោងប្រព័ន្ធទិន្នន័យស្តីពីការលើកកំពស់សិទ្ធិនៅតាមមូលដ្ឋាន ដោយពិភាក្សាជាមួយ UNDP ដើម្បីឱ្យបន្តជំនួយឧបត្ថម្ភលើគម្រោងនេះ

-ពិភាក្សាជាមួយវិទ្យាស្ថានដាណឺម៉ាក ដើម្បីសិទ្ធិមនុស្ស (DIHR) អំពីកិច្ចសហការរវាងអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ និងអង្គភាពគ្រប់គ្រងគម្រោង និងវិទ្យាស្ថានដាណឺម៉ាក ដើម្បីសិទ្ធិមនុស្ស សម្រាប់ឆ្នាំ២០០៨

-ពិភាក្សាបន្តកិច្ចសហប្រតិបត្តិការជាមួយ DANIDA និង CCJAP III ក្នុងការឧបត្ថម្ភកំណែទម្រង់ច្បាប់ និងតុលាការ សម្រាប់ ២ ឆ្នាំទៅមុខទៀត

-បន្តការពិភាក្សាជាមួយសហភាពអឺរ៉ុប (EU) ក្នុងការឧបត្ថម្ភដល់ការអនុវត្តគម្រោងខ្លះ

-ពិភាក្សាជាមួយក្រុមការងារ USAID ដើម្បីផ្តល់មតិដល់ការរៀបចំកម្មវិធីជំនួយឧបត្ថម្ភសម្រាប់រយៈ ពេល ៥ ឆ្នាំទៅមុខ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែមករា ឆ្នាំ ២០០៨*

អ្នកធ្វើរបាយការណ៍

ហ៊្លឹង សុកុល

**បានឃើញ និងឯកភាព**

នាយកអង្គភាពគ្រប់គ្រងគម្រោង

ស៊ុយ ម៉ុងលាង